-គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ -អន្តរជាតិ ។

-សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ- អន្តរជាតិ អភិបាលរាជធានីភ្នំពេញ ប្រធានគណៈកម្មការរៀបចំបុណ្យសពឯកឧត្តម ទៀប បែន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពគណៈកម្មការ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈≈≈

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០១

## សេចក្តីសំរេច លេខ ២៣ សសរ

## ស្តីពី

## ការបង្កើតក្រុមការងារសំរបសំរួលជាមួយសហគមន៍អ្នកផ្តល់ជំនួយ

~~~

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់

www.pheakdeylaw.com
~~~

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារមួយរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីសំរបសំរួលជាមួយសហគមន៍អ្នកផ្តល់ជំនួយ និងគៀងគរជំនួយបំរើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ និងការអនុវត្តន៍នយោបាយវិមជ្ឈការ ដែលរួមមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន

២-ឯកឧត្តម **យូ ហុកគ្រី** ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអនុប្រធាន

៣-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៤-ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៥-ឯកឧត្តម **អ៊ុច គឹមអន** រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៦-ឯកឧត្តម **សក់ សេដ្ឋា** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ជាសមាជិកអចិន្ត្រៃយ៍

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ច :

-សិក្សាប៉ាន់ប្រមាណអំពីតម្រូវការនានា សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងការអនុវត្តន៍នយោបាយវិមជ្ឈការ

-ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងសហគមន៍អ្នកផ្តល់ជំនួយនានាសំរាប់កម្ពុជា ដើម្បីពិភាក្សាសំរបសំរួលស្វះស្វែងរកជំនួយបំរើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងការអនុវត្តន៍នយោបាយវិមជ្ឈការ

-ពិភាក្សាស្វះស្វែងរកការគាំទ្រពីសមាគម អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ

-រៀបចំឱ្យមានកិច្ចប្រជុំជាមួយក្រសួងស្ថាប័ន នៃរាជរដ្ឋាភិបាល ឬជាមួយសហគមន៍អ្នកផ្តល់ជំនួយ ឬជាមួយសហគមន៍ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ តាមការចាំបាច់ ។

www.pheakdeylaw.com

**ប្រការ ៣** : ក្រុមការងារមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ និងចំណាយថវិការបស់គណៈរដ្ឋមន្ត្រី ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## III- ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

## សេចក្តីសំរេច

ភ្នំពេញ,ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេច លេខ ១១៦ កធស.សរ**

~~~

**រដ្ឋមន្ត្រីក្រសួង ធម្មការ និងសាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃនិកាយ " **សេះទេនះដេយអាត់ទេនទីស្ទ** " នៅខេត្តបាត់ដំបង របស់លោក **នុត មៅ** អាយុ៤៧ ឆ្នាំ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០០

www.pheakdeylaw.com
~~~